**ព្រឹទ្ធសភា**

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
## ស្តីពី
## លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែតុលា ឆ្នាំ២០២០

នៅក្នុងខែតុលា ឆ្នាំ២០២០នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ៖

### ១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

១.១ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា

-បានបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទីចាប់ពីថ្ងៃទី៦ ខែតុលា ឆ្នាំ២០២០។

ក-បដិសណ្ឋារកិច្ចជាមួយភ្ញៀវជាតិ និងអន្តរជាតិ

-បានអនុញ្ញាតឱ្យឯកឧត្តម **Anatoly BOROVIK** ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសហព័ន្ធរុស្ស៊ី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម។

ខ-សកម្មភាពចុះមូលដ្ឋាន

-បានអញ្ជើញចុះពិនិត្យស្ថានភាពជំនន់ទឹកភ្លៀង និងសាកសួរសុខទុក្ខប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់ នៅសង្កាត់គងនយ ខណ្ឌដង្កោ រាជធានីភ្នំពេញ

-បានអញ្ជើញចុះសួរសុខទុក្ខមន្ត្រី កងកម្លាំង និងអាជ្ញាធរសង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

គ-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញចូលរួមរំលែកទុក្ខក្រុមគ្រួសារសពលោកជំទាវឧកញ៉ា **កែវ ម៉ាលី** ទីប្រឹក្សាសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៅសង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមពិធីសូត្រមន្តកឋិនទានសាមគ្គី នៅវត្តសុវណ្ណារាម សង្កាត់ទួលសង្កែទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមព្រះរាជពិធីសម្ពោធមណ្ឌលសុខភាព **សម្តេចព្រះមហាសង្ឃរាជ បួរ គ្រី** ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ**



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum sarith@camnet.com.kh

**នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅវត្តព្រះឥន្ទសាមគ្គីធមិ ស្រុកអង្គស្នួល ខេត្តកណ្តាល

-បានអញ្ជើញដង្ហែព្រះរាជដំណើរ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះវររាជមាតាជាតិខ្មែរ នរោត្តម មុនិនាថ សីហនុ** ស្តេចយាងទៅពិនិត្យ និងព្យាបាលព្រះរាជសុខភាព នៅទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន។

**ឃ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានចុះហត្ថលេខាលើព្រះរាជក្រឹត្យចំនួន៨៥ច្បាប់

-បានទទួលព្រះរាជសារព្រះរាជទានសិទ្ធិចំនួន៧៣ច្បាប់

-បានទទួលសំណើពីរាជរដ្ឋាភិបាលចំនួន៧០ច្បាប់

-បានទទួលសំណើពីរដ្ឋសភាចំនួន១ច្បាប់

-បានទទួលសំណើប្រមុខរដ្ឋស្តីទីចំនួន២ច្បាប់

-បានទទួលជ្រាបជាព័ត៌មានចំនួន១៩ច្បាប់

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៩ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៣០ច្បាប់។

**១.២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ុំ កា អនុប្រធានទី១ព្រឹទ្ធសភា**

-បានទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន១លើក។

**ក-សកម្មភាពចូលរួមកិច្ចប្រជុំ**

-បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន២លើក និងសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី៦ នីតិកាលទី៤ ចំនួន១លើក។

**ខ-សកម្មភាពចូលរួមពិធីផ្សេងៗ**

-បានអញ្ជើញចុះពិនិត្យស្ថានភាពជំនន់ទឹកភ្លៀង ដែលគំរាមកំហែងដល់ប្រជាពលរដ្ឋរស់នៅក្នុងភូមិសាស្ត្រសង្កាត់រលួស ខណ្ឌដង្កោ រាជធានីភ្នំពេញ

-បានអញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកអំណោយផ្ទាល់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា ចែកជូនដល់ប្រជាពលរដ្ឋដែលកំពុងរងគ្រោះដោយជំនន់ទឹកភ្លៀងចំនួន៤៦៨គ្រួសារ ក្នុងសង្កាត់

គងនយ ខណ្ឌដង្កោ រាជធានីភ្នំពេញ

-បានអញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកអំណោយចែកជូនប្រជាពលរដ្ឋដែលកំពុងរងគ្រោះដោយជំនន់ទឹកភ្លៀងចំនួន១៥៣គ្រួសារ មកពីភូមិកំរៀង និងភូមិសេរីជីដុះ ក្នុងសង្កាត់ព្រៃវែង ខណ្ឌដង្កោ រាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមរំលែកទុក្ខ និងជាអធិបតីក្នុងពិធីប្រទានភ្លើងបូជាសពឯកឧត្តម **គីម ហេង** ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងជាប្រធាននាយកដ្ឋានរដ្ឋបាល នៃខុទ្ទកាល័យគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា នៅវត្តពោធិសត្ថារាម សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

**១.៣ ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា**

ក.សកម្មភាពចូលរួមប្រជុំ

-បានអញ្ជើញចូលរួមប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន២លើក និងសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី៦ នីតិកាលទី៤ ចំនួន១លើក ក្រោមអធិបតីភាពឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ុំ កា** ប្រធានស្តីទីព្រឹទ្ធសភា។

ខ.សកម្មភាពចុះមូលដ្ឋាន

-បានអញ្ជើញអមដំណើរឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ុំ កា** ប្រធានស្តីទីព្រឹទ្ធសភា ចុះពិនិត្យស្ថានភាពជំនន់ទឹកភ្លៀងដែលគំរាមកំហែងដល់ប្រជាពលរដ្ឋរស់នៅក្នុងភូមិសាស្ត្រសង្កាត់រលួស ខណ្ឌដង្កោ រាជធានីភ្នំពេញ

-បានអញ្ជើញអមដំណើរឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ុំ កា** ប្រធានស្តីទីព្រឹទ្ធសភា នាំយកអំណោយរបស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា ចែកជូនប្រជាពលរដ្ឋចំនួន១៥៣គ្រួសារ ដែលរងគ្រោះដោយជំនន់ទឹកភ្លៀង ក្នុងសង្កាត់ព្រៃវែង ខណ្ឌដង្កោ រាជធានីភ្នំពេញ

-បានអញ្ជើញទស្សនកិច្ចឈ្វេងយល់អំពី ហេដ្ឋារចនាសម្ព័ន្ធ ការកសាងអគារ អាងហែលទឹក ការងារពាក់ព័ន្ធវិស័យកសិកម្ម ការសិក្សាស្រាវជ្រាវ និងការពិសោធន៍បច្ចេកទេសបណ្តុះកូនចេកអំបូង និងក្រូចពោធិ៍សាត់ នៅសាកលវិទ្យាល័យបាត់ដំបង ខេត្តបាត់ដំបង

-បានអញ្ជើញជាតំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា នាំយកអំណោយចែកជូនប្រជាពលរដ្ឋចំនួន៧៥០

គ្រួសារដែលរងគ្រោះដោយជំនន់ភ្លៀង នៅខេត្តបាត់ដំបង និងខេត្តកណ្តាល។

**គ-សកម្មភាពចូលរួមពិធីផ្សេងៗ**

-បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាដាក់កម្រងផ្កា និងគោរពវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ** នៅមណ្ឌបតម្កល់ព្រះបរមរូប រាជធានីភ្នំពេញ។

**ឃ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២០ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៥ច្បាប់។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន២លើក**:

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបានបលើកកិច្ចប្រជុំចំនួន២លើក ដើម្បីពិនិត្យសំណើរបស់រដ្ឋសភាសុំពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន៩ច្បាប់ ដូចខាងក្រោម៖

១-សេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងល្បែងពាណិជ្ជកម្ម

២-សេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើ ៖

១-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃម៉ាឡេស៊ីស្តីពី ការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ

២-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ

៤-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពី ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ

៥-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពី បត្យាប័នរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង

៦-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពី ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ រវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី

៧-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាមីណាម៉ាតាស្តីពីបារត

៨-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើវិសោធកម្មពិធីសារម៉ុងរ៉េអាល់ ស្តីពី សារធាតុបំផ្លាញស្រទាប់អូហ្សូន

៩-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ានហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន

១០-ពិនិត្យ និងសម្រេចលើរបាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី៥ និងលើកទី៦ នីតិកាលទី៤។

**៣.សម័យប្រជុំពេញអង្គព្រឹទ្ធសភាចំនួន១លើក**:

ព្រឹទ្ធសភាបានបើកសម័យប្រជុំលើកទី៦ នីតិកាលទី៤ ដើម្បីស្តាប់របាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី៥ និងលើកទី៦ នីតិកាលទី៤ ព្រមទាំងពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ចំនួន៩ច្បាប់ដូចខាងក្រោម៖

១-សេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងល្បែងពាណិជ្ជកម្ម

២-សេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើ ៖

១-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃម៉ាឡេស៊ីស្តីពី ការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ

២-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ

៤-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពី ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ

៥-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើអនុសញ្ញាស្ដីពី បត្យាប័នរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង

៦-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្ដីពី ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ រវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី

៧-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើអនុសញ្ញាមីណាម៉ាតាស្ដីពីបារត

៨-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើវិសោធកម្មពិធីសារម៉ុងរ៉េអាល់ស្ដីពី សារធាតុបំផ្លាញស្រទាប់អូហ្សូន

៩-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន ហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន

១០-ពិនិត្យ និងសម្រេចលើរបាយការណ៍ស្ដីពីសកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី៥ និងលើកទី៦ នីតិកាលទី៤។

## ៤.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា

ក្នុងខែតុលានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

### ៤.១ មុខងារនីតិកម្ម

បានប្រជុំអន្តរគណៈកម្មការ ជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យសិក្សាលើសេចក្ដីព្រាងច្បាប់ចំនួន៩ច្បាប់។

### ៤.២ មុខងារតាមដានការអនុវត្តច្បាប់

-បានអញ្ជើញជួបពិភាក្សាការងារជាមួយឯកឧត្តម **ឈិត សុខុន** រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ដើម្បីឈ្វេងយល់ពីការវិវត្តរីកចម្រើនថ្មី បញ្ហាប្រឈម វិធានការ និងចក្ខុវិស័យទៅមុខរបស់ក្រសួង

-បានអញ្ជើញចុះសិក្សាឈ្វេងយល់ និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់គណៈកម្មការ និងរៀបចំវេទិកាពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្ដីពីសកម្មភាពគាំទ្រក្នុងការអភិវឌ្ឍឃុំ សង្កាត់របស់ថ្នាក់ខេត្ត ក្រុង ស្រុក នៅខេត្តកោះកុង និងខេត្តព្រះសីហនុ

-បានចុះបេសកកម្មសិក្សាឈ្វេងយល់អំពី វឌ្ឍនភាពនៃសមាហរណកម្មការិយាល័យ

ជំនាញទៅក្នុងរចនាសម្ព័ន្ធថ្មីនៃរដ្ឋបាលក្រុង ស្រុក ការអនុវត្តថវិកា និងការអភិវឌ្ឍមូលដ្ឋាន នៅខេត្តព្រះវិហារ។

**៤.៣ មុខងារតំណាង**

-បានទទួលពាក្យបណ្តឹងចំនួន៨ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយចំនួន១០ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងបានចំនួន១៥ករណី និងទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្តឹងពីស្ថាប័នពាក់ព័ន្ធចំនួន២ករណី ធ្វើលិខិតជំរុញការដោះស្រាយពាក្យបណ្តឹងចំនួន៣ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន១៥ករណី តម្កល់ទុកមិនចាត់ការចំនួន៥ករណី និងទទួលឯកសារពាក្យបណ្តឹងដែលក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ដើម្បីជូនជ្រាបចំនួន៣ករណី

-បានធ្វើវេទិកាពិគ្រោះយោបល់ស្តីពី តម្រូវការសេវាសង្គមនៅក្នុងមូលដ្ឋាន និងសំណេះសំណាលជាមួយជនចាស់ជរា អបអរសាទរទិវាមនុស្សចាស់អន្តរជាតិ នៅវត្តតិក្ខប្បញ្ញោ សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមវេទិកាពិគ្រោះយោបល់ស្តីពី សកម្មភាពគាំទ្រអភិវឌ្ឍឃុំ សង្កាត់របស់ថ្នាក់ខេត្ត ក្រុង ស្រុក នៅខេត្តកោះកុង

-បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយស្តីពី នីតិវិធីនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងដំណើរការរៀបចំការបោះឆ្នោត នៅខេត្តព្រះសីហនុ

-បានអញ្ជើញចូលរួមកិច្ចប្រជុំ និងស្តាប់បទបង្ហាញដើម្បីត្រៀមចូលរួមប្រជុំមហាសន្និបាតលើកទី២០៦ នៃក្រុមប្រឹក្សាភិបាលសហភាពអន្តរសភាIPU និងកិច្ចប្រជុំពាក់-ព័ន្ធតាមរយៈប្រព័ន្ធវីដេអូ

-បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំក្រុមការងារយុវជនផ្នែកវប្បធម៌ និងសាសនា ដើម្បីពិនិត្យពិភាក្សាអំពីផែនការសកម្មភាព និងការចុះសហការជាមួយអាជ្ញាធរមូលដ្ឋាននៅតាមរាជធានី ខេត្ត ក្នុងការជំរុញចលនាយុវជន និងសាសនា

-បានអញ្ជើញចូលរួមជាវាគ្មិនធ្វើបទបង្ហាញដល់កម្មសិក្សាការី សមាជិក សមាជិកាសមាគមសាលាត្រាជូ អំពីរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា និងដំណើរការនីតិកម្មរបស់ព្រឹទ្ធសភា

សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះជួបពិភាក្សាការងារជាមួយសមាជិក

ក្រុមប្រឹក្សាឃុំ សង្កាត់ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋរងគ្រោះដោយជំនន់ទឹកភ្លៀង ចែកអំណោយ និងអប់រំផ្សព្វផ្សាយវិធីបង្ការនិងទប់ស្កាត់ជំងឺកូវីដ១៩ ដល់ប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងចូលរួមពិធីផ្សេងៗនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តក្រុងនានាចំនួន១៧១លើក។

## ៤.៥ កិច្ចសហប្រតិបត្តិការអន្តរជាតិ

-លោកជំទាវ **ទី បូរ៉ាសុី**, ឯកឧត្តម **ជា ជេដ្ឋ**, ឯកឧត្តម **ម៉ែន ស៊ីផាន់** បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មការនយោបាយនៃសភាប្រើភាសាបារាំង និងកិច្ចប្រជុំវិសាមញ្ញរបស់បណ្តាញស្ត្រីនៃសភាប្រើភាសាបារាំង (APF) តាមរយៈប្រព័ន្ធវីដេអូ

-ឯកឧត្តម **ទេព យុទ្ធី** បានអញ្ជើញចូលរួមក្នុងវេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិច(APPFGH) ក្រោមប្រធានបទស្តីពី ការវិនិយោគក្នុងការគ្របដណ្តប់សុខភាពសកលនាពេលអនាគត តាមរយៈប្រព័ន្ធវីដេអូ

-ឯកឧត្តម **ម៉ុង ឫទ្ធី** បានទទួលជួបគណៈប្រតិភូក្រុមហ៊ុន Atomy មកពីប្រទេសកូរ៉េខាងត្បូងអំពីគម្រោងសាងសង់លំនៅដ្ឋានចំនួន១៨ខ្នង ជូនប្រជាពលរដ្ឋក្រីក្រចំនួន៣៦គ្រួសារ និងសាងសង់សាលាមត្តេយ្យចំនួន២កន្លែង នៅតំបន់អភិវឌ្ឍន៍កសិទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ ខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ។

ថ្ងៃព្រហស្បតិ៍ ១២រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

**រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០២០**

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**កិត្តិសង្គហបណ្ឌិត ទេព ងន**

*ចម្លងជូន*

- *ក្រសួងព្រះបរមរាជវាំង*
- *ក្រុមប្រឹក្សាធម្មនុញ្ញ*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ*
- *ក្រសួងយុត្តិធម៌*
- *ក្រសួងព័ត៌មាន*
- *(ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)*
- *កាលប្បវត្តិ-ឯកសារ*